CARITAS CHRISTI URGET NOS

# ជីវិត Life

“ចោរវាមក គិតតែពីលួចប្លន់ គិតតែពីសម្លាប់ និង បំផ្លាញ ប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមកដើម្បីឲ្យមនុស្ស លោកមានជីវិត ហើយឲ្យមានជីវិតយ៉ាង បរិបូរណ៍”។

(យ៉ូហាន: ១០.១០)

សកម្មភាពព្រះសហគមន៍ភូមិភាគភ្នំពេញ

លេខ១ សំរាប់ថ្ងៃទី០១-៣១ ខែតុលា ឆ្នាំ២០១១

## សម្តេចប៉ាបប្រាប់យុវជនឲ្យកសាងជំនឿឲ្យបាន រឹងប៉ឹង និងធ្វើជាសាក្សីក្នុងពិភពលោក ទំព័រ ១០-១១




■ សិស្សវិទ្យាល័យ សន្តប្រាំងស្វ័រ..... ទំព័រទី ៣

■ ភូមិសុខសាន្ត ជាភ្ញីសឡឹម..... ទំព័រទី ៤

■ យុវជនរិះគិត អំពីតួនាទី .... ទំព័រទី ៧

■ ឱកាសដ៏មាន តម្លៃរបស់ .... ទំព័រទី ១៤

# លិខិតលោកអភិបាលអូលីវីយេ



មិត្តអ្នកអានជាទីស្រឡាញ់!

ព្រឹត្តិបត្រ "ជីវិត" លេខទី១ ដែលបងប្អូនកាន់នៅក្នុងដៃនេះ ជាព្រឹត្តិបត្រព័ត៌មានពីសកម្មភាពព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

ហេតុអ្វីបានជាយើងហៅព្រឹត្តបត្រនេះថា "ជីវិត" ? គោលបំណងនៃព្រឹត្តិបត្រប្រចាំខែនេះ គឺបង្ហាញ អំពីជីវិតរបស់ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ។ ជារៀងរាល់ខែ យើងនឹងទទួលបានដំណឹងពីសកម្មភាព នៃមណ្ឌលសកម្មភាពនីមួយៗ អំពីភូមិភាគ ពីក្រុមគ្រួសារបុព្វជិតបុព្វជិតា និងពីអង្គការកាតូលិកក្នុងភូមិភាគភ្នំពេញ ។

ពីមួយសប្តាហ៍ទៅមួយសប្តាហ៍ សហគមន៍នីមួយៗ មានបទពិសោធន៍ដ៏អស្ចារ្យអំពីជំនឿ ការជួបជុំគ្នាការអធិដ្ឋាន និងអំពីជីវិត! ជាអំណរសប្បាយដែលយើងនឹងចែករំលែកជាមួយគ្នានូវបទពិសោធន៍ទាំងនោះ ដែលធ្វើឲ្យយើងស្គាល់គ្នាកាន់តែច្បាស់ឡើងៗ និងជាពិសេសលើកទឹកចិត្តគ្នា ទៅវិញទៅមកក្នុងជីវិតយើងជាគ្រីស្តបរិស័ទ ។

"*សាវ័កទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ង និងព្យាយាមអធិដ្ឋាន*" (កិច្ចការ ២.៤២) ។

សូមឲ្យព្រឹត្តបត្រ "ជីវិត" នេះលើកទឹកចិត្តយើង ឲ្យខិតខំកសាងព្រះសហគមន៍ប្រកបដោយចិត្តសន្តិភាព និងអំណរសប្បាយ ដែលមកពីព្រះជាម្ចាស់។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រុមការងារនៃការិល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ដែលជួយសម្របសម្រួលកិច្ចនេះ ហើយខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះបងប្អូនដែលបានខិតខំបង្ហាញសេចក្តីស្រលាញ់ និងធ្វើជាសាក្សីរបស់ព្រះយេស៊ូជារៀងរាល់ថ្ងៃ។

លោកអភិបាលរបស់បងប្អូន
អូលីវីយេ ជ្មីតអឺស្លែរ

Dear readers,

You are holding the first issue of "CHIVET", the new review of the Apostolic Vicariate of Phnom Penh. Chivet means "LIFE".

Why "CHIVET"? The purpose of this new monthly publication is to present the life of the Vicariate of Phnom Penh. Every month we will hear from each pastoral sector, from the diocese, from religious congregations, and from Catholic NGOs and other groups,

From week to week, each community lives great experiences of faith, meetings, and prayer. Life!

What a joy it is to share these experiences with each other in order to know each other better and above all to encourage each other in our lives as baptized followers of Jesus.

"They devoted themselves to the apostles" teaching and fellowship, to the breaking of bread and prayer." (Acts 2.42)

May "CHIVET" encourage us to build our church with a peaceful heart and with joy that comes from God.

A very special thanks to the Catholic Social Communications team who co-ordinate this work, and a million of thanks to each of you who daily give all your love in witnessing to Jesus!

Your Bishop

+Olivier Schmitthaeusler

# សិស្សនៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ ប្រឡងជាប់បាក់ឌុប ១០០%

តាមលទ្ធផលការប្រលងបាក់ឌុបចេញផ្សាយកាលពីខែកក្កដា កន្លងទៅនេះបានអោយដឹងថា សិស្សវិទ្យាល័យសន្តហ្វ្រង់ស្វ័រចំនួន ៣៦នាក់ បានប្រលងជាប់សញ្ញាបត្របាក់-ឌុប ឬសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ១០០% ក្នុងឆ្នាំសិក្សា២០១០-២០១១នេះ។ នេះជាលើកទី៣ ហើយដែលសាលាទទួលបានលទ្ធផល ដូច្នេះ។

តាមអ្នកស្រីឡៃ មករា ជានាយិកាសាលាបាននិយាយថា វិទ្យាល័យសន្តហ្វ្រង់ស្វ័រ មានការយកចិត្តទុក ដាក់ដល់គុណភាពសិក្សារបស់សិស្សម្នាក់ៗ ក្នុងនោះសាលាបានជ្រើសរើសគ្រូដែលមានសមត្ថភាព បង្កើតបណ្ណាល័យសម្រាប់ស្រាវជ្រាវ បង្រៀនគួរបន្ថែម និងផ្តល់អាហារថ្ងៃត្រង់។ អ្នកស្រីបន្ថែមទៀតថា សាលាក៏បានយកចិត្តទុកដាក់ទៅលើវត្តមានរបស់សិស្សម្នាក់ៗ ដោយមានការសហការជាមួយ នឹងមាតាបិតាឬអាណាព្យាបាល។

អ្នកស្រី មានអំណរសប្បាយ នៅពេលដែលសិស្សទទួលបានជោគជ័យនេះ ព្រោះវាបានសមស្របទៅ នឹង



គោលដៅដែលវិទ្យាល័យចង់បាន គឺធ្វើយ៉ាងណាឲ្យសិស្សទទួលបានចំណេះដឹង និងគុណភាព។ វិទ្យាល័យសន្តហ្វ្រង់ស្វ័រ ជាសាលារបស់ព្រះសហគមន៍កាតូលិកដែលបង្កើតឡើងដោយលោកអភិបាលអូលីវីយេ និងមានទីតាំងនៅ ភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

តាមរបាយការណ៍របស់ក្រសួងអប់រំបានឲ្យដឹងថា សិស្សប្រលងជាប់សញ្ញាបត្របាក់ឌុបឆ្នាំនេះមានចំនួន ៩២២៣៦ នាក់ ក្នុងចំណោមសិស្ស ១១១២៧៩នាក់។

# St. Francis high school passed BacII 100%

All 39 students from St. Francis High School who took the BacII exam for the academic year 2010-2011 passed successfully.  This is the third year that St. Francis's student can achieve. At St. Francis, the curriculum studied is the same as in the public schools,  but the salaries of the teachers are provided by the church.

Mrs. Lay Makkara, the Vice-director of the school, said the school has selected good teachers  and provides good opportunities for the students such as a library, extra classes, and free lunch. Moreover, the school has good cooperation with the parents. She added that she was proud of both the school and the students for their great effort to achieve their goals. She hopes they will have a bright future.

St. Francis is a Catholic school and was found by Mgr. Olivier Schmitthaeusler . It is located in ChamkarTieng village, Kous Commune, TramKok district in Takeo province

# ភូមិសុខសាន្ត ជាក្តីសង្ឃឹមថ្មី សម្រាប់គ្រួសារអ្នកជំងឺអេដស៍



លោកអភិបាលអូលីវីយេ បានបង្កើតមណ្ឌលសម្តេចប៉ាប យ៉ូហានប៉ូលទី២នៅភ្នំវល្លិ៍ ខេត្តកែបកាលពីឆ្នាំ២០០៣ សម្រាប់ទទួលគ្រួសារអ្នកផ្ទុក និងមានជំងឺអេដស៍ ។

ឥឡូវនេះលោកអភិបាល បានប្តូរមណ្ឌលនេះដោយលោកបានបង្កើតភូមិថ្មីមួយដែលមានឈ្មោះថា ភូមិសុខសាន្ត ហើយនៅថ្ងៃទី១៥ ខែកញ្ញា កន្លងទៅនេះ ភូមិសុខសាន្តបានទទួលស្វាគមន៍ គ្រួសារអ្នកជំងឺអេដស៍ ចំនួន៩ គ្រួសារដែលមានមនុស្ស៥០នាក់។ លោកអភិបាលមានប្រសាសន៍ថា មូលហេតុបួនសំខាន់ដែលធ្វើឲ្យលោកសម្រេចចិត្តផ្លាស់ប្តូរទីតាំងថ្មីនេះគឺ ទីមួយ គឺធ្វើឲ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងមណ្ឌល ទីពីរ គឺក្មេងៗមានភាពងាយស្រួលដើម្បីទទួលការអប់រំនៅសាលា ទីបីគឺអ្នកជំងឺមានភាពងាយស្រួលក្នុងការទទួលការព្យាបាលនៅមន្ទីរពេទ្យ ហើយមូលហេតុទីបួននោះ គឺឲ្យអ្នកជំងឺទាំងនោះមានភាពងាយស្រួលបង្កើតសកម្មភាពផ្សេងៗជាមួយព្រះសហគមន៍។

ព្រះសហគមន៍បានកសាងផ្ទះចំនួន ៨ខ្នង សម្រាប់គ្រួសារអ្នកជំងឺ ហើយក៏ជាមណ្ឌលសំរាប់កុមារពិការដោយមានការសហការជាមួយអង្គការក្នុងស្រុក នឹងការគាំទ្រដោយលោកអភិបាលអូលីវីយេ ជាច្រើនឆ្នាំមកហើយ។

នៅទីនោះព្រះសហគមន៍មានដី ៦ហិចតា ដើម្បីឲ្យពួកគាត់ធ្វើកសិកម្ម។ បើតាមលោកឃិន អានលី ជាអ្នកជំងឺអេដស៍ មានអាយុ៣២ឆ្នាំ មានកូនបួននាក់បានរៀបរាប់ថា កាលពីមុនគ្រួសារអ្នកជំងឺអេដស៍បានមកភ្នំវល្លិ៍ ក្នុងគោលបំណងដើម្បី ទទួលការព្យាបាលជម្ងឺរបស់ខ្លួនតាមរយៈគ្រូខ្មែរ ប៉ុន្តែបន្ទាប់ពីលោកអភិបាលអូលីវីយេទៅដល់ទីនោះគ្រួសារអ្នកជំងឺអេដស៍ទាំងនោះ បានទទួលការជ្រុំជ្រែងពីសំណាក់លោកអភិបាលវិញ។ លោកក៏បានបន្ថែមទៀតថា លោកអស់សង្ឃឹមពេលដែលដឹងថា ខ្លួនផ្ទុកមេរោគនេះ តែដោយមានការគាំទ្រពីលោកអភិបាល នាំឲ្យលោកមានក្តីសង្ឃឹមឡើងវិញ។ ភូមិសុខសាន្តស្ថិតនៅ ភូមិពោងទឹកខាងត្បូង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

John Paul II Center was found by Bishop Olivier Schmitthaeusler in 2003 at Phnom Vor, Kep province for HIV/AIDS. Now it is time to move the original center to a new location the Bishop has in “Peace Village”.

Bishop Olivier said there are four main reasons why he decided to move the center. First, it is easier to manage the HIV/AIDS families at the new center. Second, children can go to school easily at there. Third, the new center makes it easier for its clients to receive health care service from the local hospital. And finally, the clients of the center will be closer to the church.

In this village that is also a Children with Disabilities Day Care Center with DYCFE local NGO which supported by Bishop Olivier since many years.



Disable Children Day Care Center

# វិទ្យាស្ថាន សន្តប៉ូល ជ្រើសរើសនិស្សិតសម្រាប់ ឆ្នាំសិក្សា ២០១១-២០១២

វិទ្យាស្ថានសន្តប៉ូលមានកិត្តិយសសូមជម្រាបដល់សិស្សានុសិស្ស ដែលបានប្រលងជាប់សញ្ញាបត្រទុតិយភូមិ ទាំងអស់ឲ្យបានជ្រាបថា ក្នុងឆ្នាំសិក្សា២០១១-២០១២ វិទ្យាស្ថាន ត្រូវការជ្រើសរើសនិស្សិតឲ្យចូលសិក្សានូវមុខវិជ្ជាដូច បរិញ្ញាបត្រពត៌មានវិទ្យា បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ បរិញ្ញាបត្រអក្សរសាស្រ្តអង់គ្លេស បរិញ្ញាបត្រក្សេត្រសាស្រ្ត។

ការសិក្សាពេញម៉ោងចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ។ ថ្លៃសិក្សាក្រោមជំនួយឧបត្ថម្ភ៥០% ពីលោកនាយកវិទ្យាស្ថានរួចជាស្រេច។ ឆ្នាំទីមួយ បង់ថ្លៃ១៨០ដុល្លារ ក្នុងមួយឆ្នាំ ហើយឆ្នាំទី២ ទី៣ និងទីបួនបង់ថ្លៃសិក្សាចំនួន ២៥០ដុល្លារ ក្នុងមួយឆ្នាំ។ វិទ្យាស្ថានមានគោលការណ៍ផ្តល់អាហាររូបករណ៍បន្ថែមដល់និស្សិតក្រីក្រ ដែលពុំមានលទ្ធភាពចូលរៀនចាប់ពី ២៥%ដល់ ១០០% តាមលក្ខខណ្ឌសង្គម និង មានមណ្ឌលសំរាប់ឲ្យនិស្សិតមកពីខេត្តផ្សេងៗស្នាក់នៅក្នុងពេលកំពុងសិក្សាដោយឥតគិតថ្លៃ។

ទទួលពាក្យចូលរៀនចាប់ពីថ្ងៃទី១ ខែសីហា រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១។ ឆមាសទី១ និងត្រូវចូលរៀននៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១។

សូមបញ្ជាក់និស្សិតដែលចុះឈ្មោះចូលសិក្សាមុនថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១១ និងទទួលបានការរៀនវគ្គបំប៉នភាសាអង់គ្លេស និងកុំព្យូទ័រដោយឥតគិតថ្លៃ។

ទំនាក់ទំនងព័ត៌មានលំអិត សូមទាក់ទងវិទ្យាស្ថានសន្តប៉ូល ដែលមានទីតាំងស្ថិតនៅ ភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ (ខាងជើងផ្សារអង្គតាសោម ចម្ងាយ ៣គីឡូម៉ែត្រ)

ទំនាក់ទំនងតាមទូរស័ព្ទ: ០៣២ ៦៣៩ ០០៣
០១២ ៥១៦ ៣៣៤.

**New academic Year at Saint Paul Institute**

The Saint Paul Institute is pleased to announce to all students who just passed the Bac II exam in the academic year 2010-2011 that they can study the following Bachelor degree programs: Bachelor of InformationTechnology, Bachelor of Tourism Management, Bachelor of English Literature, and Bachelor of Agronomy.

For more information please contact: 032 639 003
012 516 334.



# សន្និបាតកុមាររបស់មណ្ឌលសកម្មភាពភ្នំពេញ

កុមារដែលមានអាយុចាប់ពី១១ ដល់១៣ឆ្នាំ ប្រហែល ១៣០នាក់មកពីព្រះសហគមន៍ចំនួន ១២នៅក្នុងមណ្ឌលសកម្មភាពភ្នំពេញបានមកចូលរួមសន្និបាត រយៈពេលបីថ្ងៃនៅព្រះសហគមន៍សន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។

សន្និបាតនេះបានរៀបចំឡើង ពីថ្ងៃទី២៥រហូតដល់ថ្ងៃទី ២៨ សីហា ឆ្នាំ២០១១កន្លងទៅនេះ។ គោលបំណងនៃអង្គសន្និបាតនេះគឺចង់ឲ្យក្មេងៗយល់អំពីភាពដ៏វិសុទ្ធរបស់សន្តសន្តី។ បងប្រុសសុខ ណា អ្នករៀបចំកម្មវិធីម្នាក់បាននិយាយថា យើងធ្វើដូច្នេះព្រោះយើងយល់ឃើញថា ក្មេងៗមានចិត្តបរិសុទ្ធ ដូចព្រះយេស៊ូមានព្រះបន្ទូលនៅក្នុងគម្ពីរ។ តាមរយៈជីវិតក្មេង យើងមានសេចក្តីសង្ឃឹមថាពួកគេនឹងក្លាយទៅជាអ្នកដែលស្រឡាញ់យុត្តិធម៌ និងសេចក្តីពិតដូចសន្ត សន្តីដែលគេបានស្គាល់។

ដើម្បីឲ្យកុមារទាំងនោះទទួលបានចំណេះដឹង ក្រុមអ្នកស្ម័គ្រចិត្តបានរៀបចំសកម្មភាពផ្សេងៗដូចជា មើលវីដេអូអំពីគ្រួសារដ៏វិសុទ្ធរបស់ព្រះយេស៊ូ សម្តែងជាតួអង្គសន្តយ៉ូហាន បូស្កូ និងការសម្តែងរឿង គូរគំនូរជាដើម។ ក្នុងសន្និ-បាតនេះ មានការលើកយកគំរូសន្ត យ៉ូហាន បូស្កូ មកឲ្យកុមារពិភាក្សា ព្រោះជីវិតរបស់គាត់ភ្ជាប់ទៅនឹងកូនក្មេង និងយុវជន។ ជាងនេះទៅទៀតសន្និបាតនេះនាំឲ្យក្មេងៗយល់ពីព្រះយេស៊ូ និងស្រលាញ់ជីវិតជាគ្រីស្តបរិស័ទដោយសុខចិត្តរស់នៅជាប់នឹងព្រះគ្រីស្តដូចសន្តសន្តីមួយចំនួន។

កញ្ញាអន ម៉ាលីន អ្នកស្ម័គ្រចិត្តម្នាក់បានសម្តែងការរំពឹងទុកថា កុមារទាំងនោះបានទទួលនូវអំណរជាមួយក្មេងដទៃទៀត ហើយគេក៏នឹងទទួលសេចក្តីស្រលាញ់ពីសំណាក់បងៗដែលជាអ្នកស្ម័គ្រចិត្ត ជាងនេះទៅទៀតគឺកញ្ញាសង្ឃឹមថា ក្មេងៗទាំងនោះនឹងទទួលចំណេះដឹងពីជីវិត និងការរស់នៅដ៏សាមញ្ញតាមគំរូរបស់ សន្តសន្តីដែលបានស្គាល់។



# Children Camp at St. Joseph

About 130 children from different parishes in the Phnom Penh Pastoral Center came together for a 3-day Children's Camp at St. Joseph Church at Phsar Tauch.

The Children's Camp was held from August 24-28, 2011 and the goal was to help the children become aware of the holiness of the saints.

Brother Sok Na said that children are pure at heart, as Jesus says in the Bible, and he hopes that these children will become lovers of justice and truth in the future.

There were different activities which helped them to gain a deeper understanding of the theme.These included watching a video on the Holy Family, a drama about Saint John Bosco, etc.

Miss On Malin, a youth volunteer, said that the camp aimed to bring the children together with joy and love. She said that it was above all an opportunity to understand the simplicity of the lives of saints.

# យុវជនរិះគិតអំពីតួនាទីរបស់ខ្លួននៅក្នុងព្រះសហគមន៍

យុវជន៣០នាក់ មកពីព្រះវិហារសន្តយ៉ូសែប នៃព្រះសហគមន៍ក្តីកណ្តាល និងយុវជនមកពីព្រះវិហារសន្តសិលា នៃព្រះសហគមន៍ពោធិ៍ធំ បានរួបរួមគ្នាជាក្រុមតែមួយដើម្បីចូលរួមសំណាក់ធម៌នៅព្រះវិហារសន្ត យ៉ូសែប (ផ្សារតូច) ភ្នំពេញ និងនៅកំពង់សោម។

ពិធីសំណាក់ធម៌នេះបានដំណើរការឡើងកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ក្រោមដឹកនាំដោយ លោកបូជាចារ្យ អាន។ នៅក្នុងពិធីសំណាក់ធម៌នោះគេបានផ្តោតលើប្រធានបទ បីសំខាន់ៗដែលត្រូវបានលើកមករិះគិតក្នុងកម្មវិធីនេះរួមមាន ការត្រាស់ហៅរបស់ព្រះជាម្ចាស់ អត្តសញ្ញាណយុវជនកាតូលិក និងតួនាទីរបស់យុវជននៅក្នុងព្រះសហគមន៍។

លោកបូជាចារ្យ អានបានមានប្រសាសន៍ថាគោលបំណងនៃការធ្វើសំណាក់ធម៌នេះគឺចង់ឲ្យយុវជនទាំងពីរព្រះសហគមន៍អាចនឹងរួបរួមគ្នាជាក្រុមតែមួយ នៅពេលខាងមុខ។ លោកបានពោលថា វាជាឱកាសមួយល្អសម្រាប់ពួកគេដើម្បីមានទំនាក់ទំនងគ្នា និងស្គាល់គ្នាកាន់តែច្បាស់ដោយយល់ពីបញ្ហា និងទុក្ខលំបាកគ្នាទៅវិញទៅមក។

លោកបូជាចារ្យ វ៉ាំងសង់ សេនីយ៍ឆាលបានណែនាំឲ្យយុវជនរិះគិតអំពី ការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងតួនាទី ជាបូជាចារ្យ បងប្រុសបងស្រី ហើយជាងនេះទៅទៀតនោះគឺចង់ឲ្យគេម្នាក់ៗយល់ថា ព្រះជាម្ចាស់បានត្រាស់ហៅគេឲ្យក្លាយទៅជាគ្រីស្តបរិស័ទម្នាក់ ហើយមានតួនាទីផ្សេងៗគ្នាក្នុងព្រះសហគមន៍ ក៏ដូចជានៅក្នុងសង្គមផងដែរ។



នៅចុងបញ្ចប់នៃការសំណាក់ធម៌អស់រយៈពេលបីថ្ងៃ យុវជនបានយល់ព្រមធ្វើការសហការណ៍ជាមួយគ្នា ដោយសុខចិត្តរួបរួមគ្នាក្នុងសកម្មភាពផ្សេងៗ ដែលមានក្នុងព្រះសហគមន៍ ជាងនេះទៅទៀតគឺពួកគេត្រូវយល់ព្រមក្នុងការប្រើប្រាស់ភាសាតែមួយ គឺជាភាសាខ្មែរទោះបីជាមានយុវជន ជនជាតិវៀតណាម ក៏ដោយ។ បន្ថែមទៀតគឺ គេត្រូវតែបំភ្លេចបញ្ហា រវាងជាតិសាសន៍ វប្បធម៌ និងប្រវត្តិសាស្ត្រ ដើម្បីឲ្យយើងឈានទៅរកការរួបរួមគ្នាជាធ្លុងតែមួយបាន។

## Kdey Kandal and Po Thom Youth Retreat

Over 30 youth from St. Joseph Church of KdeyKandal Parish and St. Peter Church of Po Thom Parish gathered together for a retreat at St. Joseph Parish (Phsar Tauch) and in Preah Sihanouk province.

The retreat was led by Fr. Ann from July 27-29, 2011. The main purpose of this retreat was to bring the youth in the two parishes together so they can be united as one group in the future.

“It’s a good opportunity for them to be with each other and get to know clearly about their problems and difficulties”, said Fr. Ann.

# សកម្មភាពមណ្ឌល ក្រុងព្រះសីហនុ



ព្រះវិហារសន្ត មីកាអែលគឺជាព្រះវិហារដែលបានរួចផុតពីការបំផ្លិចបំផ្លាញពីសម័យសង្គ្រាមស៊ីវិល។ វាត្រូវបានកសាងឡើងនៅឆ្នាំ១៩៦៤ ដោយលោកអភិបាលអ៊ីវរ៉ាមូស។ ព្រះសហគមន៍មានសកម្មភាព ដូចជាពិនិត្យ និងព្យាបាលធ្មេញ ការបង្រៀនភ្លេង ការបង្រៀនពីអនាម័យក្នុងគ្រួសារ សួរសុខទុក្ខអ្នកជាប់ពន្ធនាគារ អ្នកជំងឺនៅមន្ទីរពេទ្យ និងជួយកសាងផ្ទះរបស់ អ្នកក្រីក្រ ។

ST. MICHAEL PARISH is a Catholic Church building in Cambodia that was not destroyed during the civil war. It was founded and built by Msgr.Yves Ramousse, MEP. There are various activities in the parish such as a dental service, music class, teaching proper hygiene at home, visiting prisoners, patient visitation, and repairing houses for the less fortunate.

ភូមិម៉ាយូ ដែលមាន៣០គ្រួសារកំពុង រស់នៅហើយប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ភូមិនេះជា ភូមិដាច់ស្រយាល ហើយសាលារៀនមានចម្ងាយប្រហែល ១៥គីឡូម៉ែត្រពីភូមិ។ នៅភូមិនោះក្មេង ភាគច្រើនមានអាយុចាប់ពី ៥ដល់ ៧ឆ្នាំ។ ពួកគេទាំងនោះពុំដែលមានឱកាសទៅទទួលការអប់រំនៅសាលាទេ។ ជាហេតុព្រះសហគមន៍ បានផ្ដល់កន្លែងសម្រាប់បង្រៀន និងផ្គត់ផ្គង់សម្ភារៈសិក្សា សម្រាប់សាលាផងដែរ ហើយព្រះសហគមន៍ក៏បានផ្ដល់ប្រាក់ឧបត្ថម្ភ សម្រាប់គ្រូបង្រៀនផងដែរ។

Ma-u Village is composed of around 30 families who support themselves by farming. The nearest school is approximately 15 kilometers, far from this village. Most of the children from age 7 to 15 have never gone to school, so



since October, 2009, the Church has extended help to repair the places for studying and it has also provided school materials. The salaries of the teachers were provided by the CCBO until March, 2011 but starting in April, 2011, the church provides the salaries to continue the literacy program.

# លោកអូលីវីយេ៖ ប្រភពនៃធម៌មេត្តាករុណា គឺព្រះជាម្ចាស់

យើងត្រូវស្រឡាញ់ដោយចិត្តស្មោះ និងសេចក្តីស្រឡាញ់ត្រូវចេញជាសកម្មភាព។ លោកអភិបាលអូលីវីយេ ជ្មីតអីស្លែរ ជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ដូច្នេះ នៅក្នុងអង្គសន្និបាតកិច្ចការសង្គហៈភូមិភាគភ្នំពេញ ដែលធ្វើឡើងកាលពីថ្ងៃទី១ ខែកញ្ញាកន្លងទៅនេះ។

សន្និបាតនេះ ធ្វើឡើងរយៈពេល ៤ថ្ងៃ គឺចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៤ ខែកញ្ញា នៅព្រះវិហារសន្តយ៉ូសែប នារាជធានីភ្នំពេញ ដែលមានមនុស្សប្រមាណជិត២០០នាក់ ក្នុងនោះភាគច្រើនជាគ្រីស្តបរិស័ទ និងបុគ្គលិកនៃអង្គការកាតូលិក និងអង្គការមិនមែនកាតូលិកដែលមានសកម្មភាពបម្រើអ្នកក្រីក្រ និងអ្នកជំងឺ។

គណៈកម្មាធិការសង្គហៈ គឺជាក្រុមមួយដែលធ្វើការងារក្នុងនាមព្រះសហគមន៍ ក្នុងមុខងារបង្ហាញធម៌មេត្តាករុណាអំពីព្រះជាម្ចាស់ទៅកាន់អ្នកដទៃ។

លោកបានមានប្រសាសន៍បន្ថែមថា ប្រភពនៃធម៌មេត្តាករុណា គឺជាព្រះជាម្ចាស់។ ហើយធម៌មេត្តាករុណាសេចក្តីស្រឡាញ់នោះ នាំឲ្យយើងក្លាយជាមនុស្សដ៏វិសុទ្ធ និងអាចជួយអ្នកដទៃឲ្យក្លាយជាមនុស្សដ៏វិសុទ្ធបានតាមសកម្មភាពដែលយើងរាល់គ្នាបានធ្វើ។

ក្នុងនោះដែរលោកក៏បានលើកទឹកចិត្តដល់ព្រះសហគមន៍ដែលមានគ្រីស្តបរិស័ទតិចតួច ឲ្យបង្កើតជាគណៈកម្មាធិការសង្គហៈ ដើម្បីធ្វើសកម្មភាពឲ្យបានច្រើនដោយចាប់អារម្មណ៍លើអ្នកខ្វះខាត។ ជួយដោះស្រាយគ្នាចំពោះបញ្ហាដែលកំពុងកើតមាន ជាពិសេសគឺចំពោះជំនួយថវិកាដែលត្រូវប្រើប្រាស់សម្រាប់គណៈកម្មាធិការនេះ។

## Bishop Olivier: God is the source of mercy

A seminar on the church's social outreach and charitable activiteswas held on September 1-4, 2011 at St. Joseph Parish in PhsarTauch. The four-day seminar was focused on the Charitable activities of the diocese and on the dignity of women.

"We have to love with a true heart, a love that is shown in action," Bishop Olivier said.



# សម្តេចប៉ាបប្រាប់យុវជនឲ្យកសាងជំនឿឲ្យបានរឹងប៉ឹង

ទិវាយុវជនពិភពលោកដែលជាជំនួបយុវជនសកលលោកត្រូវបានប្រព្រឹត្តធ្វើឡើងនៅទីក្រុងម៉ាឌ្រីត ប្រទេសអេស្ប៉ាញកាលពីថ្ងៃទី១៦ ដល់២១ សីហា ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់សម្តេចប៉ាប បេណេឌីកតូទី១៦។

ក្នុងជំនួបជាមួយយុវជននាពេលនោះ សម្តេច ប៉ាប បានស្នើឲ្យយុវជនទាំងអស់ដោយរួមទាំងក្រុមយុវជនខ្មែរដែលមានឱកាសចូលរួមទិវានោះរក្សា និងកសាងជំនឿឲ្យបានរឹងប៉ឹងលើព្រះគ្រីស្ត។

នៅឱកាសនោះ នារាត្រីថ្ងៃចុងក្រោយនៃទិវាយុវជនពិភពលោក យុវជនទាំងអស់ដែលមានចំនួនប្រហែល ២ លាននាក់ បានជួបជុំគ្នានៅលើទីវាលនៃព្រលានយន្តហោះមួយ សម្តេចប៉ាប បានមានប្រសាសន៍ថា ព្រះជាម្ចាស់ស្រលាញ់យើង ហើយព្រះអង្គបានត្រាស់ហៅយើងអោយធ្វើជាមិត្ត សំលាញ់របស់ព្រះអង្គ។

សម្តេចប៉ាប បានបន្តទៀតថា ជំនឿមិនមែនចាប់ផ្តើមពីចំណេះដឹងដែលយើងយល់ពីព្រះអង្គនេះទេ តែវាគឺជាការចាប់ផ្តើម ពីអំណោយទានដែលព្រះអង្គស្រលាញ់យើង និងព្រះអង្គបានផ្តល់ឲ្យនៅក្នុងមនុស្សគ្រប់ៗរូប។ ជំនឿនាំឲ្យយើងមានទំនាក់ទំនងផ្ទាល់ជាមួយព្រះគ្រីស្ត ដោយសុខចិត្តផ្ញើជីវិតទាំងស្រុង លើព្រះអង្គអស់ពីចិត្ត និងអស់ពីអារម្មណ៍ ហើយវាស្តែងចេញជាសកម្មភាពការបម្រើ និងស្រលាញ់បងប្អូន។ មិនត្រឹមតែប៉ុណ្ណោះ យើងត្រូវនៅជាប់ជាមួយនឹងព្រះសហគមន៍ជានិច្ច ព្រោះយើងមិនអាចដើរតាមព្រះជាម្ចាស់តែម្នាក់ឯង។

កញ្ញា ចាន់ ធី តំណាងយុវជនមកពីព្រះសហគមន៍ក្រុងព្រះសីហនុបានសម្តែងអារម្មណ៍រំភើប ព្រោះនេះគឺជាព្រឹត្ត-ការណ៍អស្ចារ្យក្នុងជីវិតរបស់នាង ដែលអាចឲ្យនាងជួបយុវជន ផ្សេងៗទៀតនៅលើពិភពលោក។ នាងបន្តទៀតថា ការជួបសម្តេចប៉ាបផ្ទាល់ទើបធ្វើអោយនាងមានការភ្ញាក់ស្មារតីព្រោះតាមរយៈអ្នកដែលនៅជុំវិញនាងដែលពោរពេញទៅដោយអំណរសប្បាយក្នុងការរង់ចាំទទួលលោក។ ទាំងនេះធ្វើអោយជំនឿរបស់នាងកាន់តែកើនឡើង ហើយនាងចង់អោយយុវជនទាំងអស់ទទួលបានអារម្មណ៍ដូចនាងដែរ។



Pope Benedict tells Youth to Build their faith on Christ and share it with the World

World Youth Day 2011 was held in Madrid, Spain from 16-21 August with Pope Benedict XVI in attendance. Probably 193 different countries participated in this world-wide event.

31 Cambodian youth joyfully attended the program. The Cambodian pilgrims first went to Rome, which Bishop Olivier described as the heart of the Church. Then they headed to Madrid to join the World Youth Day program.

# ូំង និងធ្វើជាសាក្សីក្នុងពិភពលោក



ខាងក្រោមនេះដំណើរបូជនីយចរ នៅទីក្រុងរ៉ូម រៀបចំចិត្តគំនិតចូលរួមទិវាយុវជនពិភពលោក



# យុវជនព្រះសហគមន៍កំពត ធ្វើពិធីសំណាក់ធម៌ជំហានទីមួយ

យុវជនចំនួន២៨នាក់ មកពីព្រះសហគមន៍ចំនួន៤ នៅក្នុងមណ្ឌលសកម្មភាពកំពត បានជួបជុំគ្នាធ្វើពិធីសំណាក់ធម៌ទទួលជំហានទីមួយ។

ពិធីសំណាក់ធម៌នេះដឹកនាំដោយលោកបូជាចារ្យ អ៊ុន សុន លោក ចន លូកា និង លោកគ្រូឌួង សារង្ស។

គោលបំណង ក្នុងការរៀបចំកម្មវិធីសំណាក់ធម៌នេះ គឺចង់ឲ្យបងប្អូន ដែលទទួលជំហានទីមួយយល់ឲ្យកាន់តែស៊ីជម្រៅ អំពីអត្ថន័យ ការយកព្រះគ្រីស្តជាទីពឹង ការយកព្រះបន្ទូលជាទីពឹង និងព្រះសហគមន៍ជាទីពឹងព្រោះវាជាជំនឿរបស់ព្រះសហគមន៍កាតូលិក ។

លោក កែវ ភោគ ជាគ្រូអប់រំជំនឿបានអោយដឹងថា ការយកព្រះគ្រីស្តជាទីពឹងមានន័យថា យកព្រះយេស៊ូជា គំរូ ការយកជាគំរូនេះមានន័យមួយទៀតគឺ ស្រលាញ់នឹងកិច្ចការដែលព្រះយេស៊ូបានប្រព្រឹត្តកាលព្រះអង្គនៅលើផែនដី។ រីឯការយកព្រះបន្ទូលជាទីពឹងគឺមានន័យថា យើងធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងធ្វើអោយព្រះបន្ទូល របស់ព្រះអង្គកើតជារូបរាង្គ ហើយផ្តល់ផលផ្លែក្នុងជីវិតរស់នៅសម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃ។ ជាចុងបញ្ចប់គឺអត្ថន័យនៃការយកព្រះសហគមន៍ជាទីពឹង ព្រះសហគមន៍ជាមហាគ្រួសាររបស់ព្រះយេស៊ូ យើងរស់នៅក្នុងចំណោមបងប្អូនគ្រីស្តបរិស័ទឯទៀតៗ។ ដូច្នេះអ្វីដែលយើងត្រូវធ្វើគឺត្រៀមខ្លួនជាស្រេចក្នុងការចែករំលែកមិនយកផលប្រយោជន៍សម្រាប់តែខ្លួនឯងទេ។

លោកបានបន្តទៀតថា នេះជាមោទនភាព ក្នុងការក្លាយជាគ្រីស្តបរិស័ទ ហើយបានចូលរួមក្នុងព្រះសហគមន៍ ប៉ុន្តែយើងត្រូវត្រៀមខ្លួនជានិច្ចក្នុងការគោរពបងប្អូនដទៃទៀតដែលមានជំនឿផ្សេងពីយើង ជាពិសេសយើងនៅតែគោរពប្រពៃណីវប្បធម៌ និងសង្គមជាតិយើង។

កញ្ញា ធី ចាន់ធាន អាយុ១៩ឆ្នាំមកពីគ្រួសារជាពុទ្ធ-បរិស័ទ បានសម្តែងអារម្មណ៍សប្បាយរីករាយក្នុងការទទួលជំហានទី១ ព្រោះនាងបានចាប់ផ្តើមរៀនស្គាល់ព្រះជាម្ចាស់



សេចក្តីស្រលាញ់ និងការមានទំនាក់ទំនងល្អជាមួយអ្នកដទៃ។ នាងបានបន្ថែមថា នាងហាក់បីដូច ជាមនុស្សថ្មីព្រោះជីវិតជាគ្រីស្តបរិស័ទ ធ្វើឲ្យនាងបានក្លាយទៅជាមនុស្ស មានចិត្តអត់ធ្មត់ និងមានទំនាក់ទំនងល្អជាមួយអ្នកដទៃ និងមានការយោគយល់គ្នាទៅវិញទៅមក។

យុវជនទាំង២៨នាក់គឺ មកពីព្រះសហគមន៍ ជុំគីរី កោះស្លា ព្រែកប្រស់ និងកំពតហើយបានប្រព្រឹត្តធ្វើឡើងនៅខេត្តកំពតកាលពីថ្ងៃទី១២ ដល់១៣ សីហា ឆ្នាំ២០១១ កន្លងទៅនេះ។

About 28 youth from different parishes in the Kampot Pastoral Center came together for a two-day retreat and took the first step in the catechetical program, from August 12-13.

Mr. Keo Pork , a catechist, said that this was a great time to gain a deeper understanding of the Christian life.

There are core things that we have to understand before becoming a Catholic, such as taking Christ as our refuge. We take the word of God as our refuge-the word of God is our wisdom. And we take the church as our refuge-the Church is a big family.

# យុវជនបែលហ្ស៊ិក កសាងផ្ទះជូនអ្នកក្រីក្រនៅកំពត

**ញឹប ញឿន**

ក្រុមយុវជនមួយក្រុមដឹកនាំដោយលោកឪពុក រេណេហ្សុប មកពីប្រទេសបែលស៊ិក បានរៀបចំកម្មវិធីកសាងផ្ទះជូនអ្នកក្រីក្រចំនួនពីរខ្នង និងលាបថ្នាំសាលារៀននៅខេត្តកំពត ។

លោកកែវ ភោគ បានឲ្យដឹងថា កម្មវិធីនេះបានដំណើរការកាលពីថ្ងៃទី៤ ដល់ទី៨ កក្កដាកន្លងទៅនេះ នៅភូមិព្រែកប្រស់ និងភូមិនរាយ ក្នុងខេត្តកំពត ។



លោក បានឲ្យដឹងថា នេះជាសកម្មភាពលើកទីបួនដែលគេបានធ្វើនៅខេត្តកំពត ដោយមានទំនាក់ទំនង តាមរយៈលោកពុកអ៊ុន សុន ។ លោកបានបន្តទៀតថា យុវជនទាំងអស់នោះជាសិស្ស ហើយគេមកប្រទេសកម្ពុជា នៅក្នុងពេលសំរាកពីការសិក្សា ដើម្បីមានបទពិសោធន៍ជាមួយបងប្អូនក្រីក្រ ។

លោកឪពុកអ៊ុន សុន បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពកំពតប្រសាសន៍ថា ព្រះសហគមន៍មានតំរូវការជាច្រើន ដូច្នេះលោកចាត់ទុកសកម្មភាពមួយនេះថាជាការសម្រួលបន្ទុកមួយផ្នែករបស់ព្រះសហគមន៍ ហើយសំខាន់ជាងនេះទៅទៀត គឺវាបង្ហាញពីសេចក្តីស្រលាញ់ការយកចិត្តទុកដាក់ និងចំណងមិត្តភាពរវាងសិស្សបែលហ្ស៊ិក-កម្ពុជា ។ លោកឲ្យដឹងទៀតថា តាមរយៈសកម្មភាពនេះ យើងអាចនាំព្រះវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងចំណោមអ្នកក្រីក្រ ហើយវាជាបទពិសោធន៍មួយល្អដើម្បីឲ្យអ្នកនៅជុំវិញនោះស្គាល់ពីព្រះសហគមន៍ផងដែរ ។

## Belgium Youth Build House for Poor Cambodian Villagers in Kampot

A group of students from Belgium came to Cambodia to participate in voluntary service in the Kompot Pastoral Centre.

During the four days of July 4th-8th, 2011, they built 3 houses for three poor families in Prek Pros and Noreay. They also helped paint the school in the village, said Mr. Keo Pork.

According to Mr. Keo, this is the fourth time they have done this kind of work with poor Cambodian families .They do it because they want to share their lives with Cambodian people.

Fr. Un Son, the priest in charge of the Kompot Pastoral Centre, said that the Church needs such help and that he was very glad to welcome them to share with the poor whatever little they had. “Their presence in Cambodia especially, in the Kompot Pastoral Center, is very important and is a great opportunity to build a firm relationship between the church in Cambodia and Belgium”, he said.

# ឱកាសដ៏មានតម្លៃរបស់កុមារនៅសហគមន៍វៀតណាម

ញ៉ឹប ញៀន

កុមារជនជាតិវៀតណាមចំនួន ៣៧នាក់ មកពីព្រះសហគមន៍ចំប៉ា និងកោះនរាបានមកធ្វើការប្រឡងសាកល្បងសមត្ថភាពចំណេះដឹង ដើម្បីត្រៀមចូលរៀននៅសាលារដ្ឋនៅព្រះសហគមន៍ព្រះកុមារយេស៊ូ ហៅបឹងទំពុន កាលពីពេលថ្មីៗនេះ។

បងប្រុសសុខ ណា មានប្រសាសន៍ថា នេះជាការល្អ ព្រោះព្រះសហគមន៍ក៏មាន គំនិតចង់ឲ្យកុមារដែលរស់នៅក្នុងសហគមន៍វៀតណាម អាចទទួលបានការអប់រំដូចប្រជាជនខ្មែរ ព្រោះពួកគេមានឯកសារអនុញ្ញាតឲ្យរស់នៅស្រុកខ្មែរ។



លោកបានកត់សម្គាល់ឃើញថា ទោះបីជាពួកគេមួយចំនួនបានរៀនដល់ថ្នាក់ទី៤ រឺទី៥ តែពួកគេ នៅមានបញ្ហាក្នុងការអាន និងការសរសេរ ព្រោះបរិយាកាសដែលគេមានក្នុងការរៀនសូត្រ ពុំសូវផ្តល់អំណោយផលដល់គេប៉ុន្មានទេ។

លោកបានបន្តថា មានក្មេងជាច្រើននាក់ទៀតដែលបានសុំគាត់ដើម្បីចូលរៀនក្នុងសាលារដ្ឋ តែដោយសារចំនួនមានកំណត់ទើប គេសម្រេចចិត្តជ្រើសរើសតែក្មេងចំនួន ៣៧ នាក់ នោះ។

ការប្រលងសាកល្បងសមត្ថភាព ចំនេះដឹងនេះបានរៀបចំដោយ លោកម៉ារីយ៉ូ និងបងប្រុសប៊ីលប៊ឺន ដោយមានការសហការគ្នារវាងអង្គការម៉ារីណុល និងសាលារដ្ឋកុមារដែលនៅសហគមន៍វៀតណាម។

# New hope for Vietnamese Children

At least 37 children from the Vietnamese communities of Champa and KohNorea came to take a test at Child Jesus parish in Boeung Tumpun inorder to prepare for the new curriculum in the public schools in Phnom Penh.

Brother Sok Na said that this was a great opportunity for them.

Brother observed that most of the children are poor and have weak knowledge. Eventhough some of them are in grade fourth or fifth, they still can't read and write well.

He added that many more children asked him for this opportunity but unfortunately as of now they can accept only a limited number.

The test was made possible by cooperation among the church, Maryknoll, and the public school in order to offer a new opportunity for Vietnamese children to get more education.

# ជំនួបអង្គការកាតូលិកប្រចាំភូមិភាគភ្នំពេញ



អង្គការ និងសមាគមកាតូលិក ដែលកំពុងមានសកម្មភាពនៅក្នុងព្រះសហគមន៍ភូមិភ្នំពេញ បានជួបជុំគ្នាចែករំលែកបទពិសោធន៍ និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកក្រោមអធិបតីភាពរបស់លោក អូលីវីយេ ជ្មីតអីស្លែរ អភិបាលព្រះសគមន៍ភូមិភ្នំពេញ កាលពីថ្ងៃទី១២ ខែកញ្ញាកន្លងទៅ នៅការិយាល័យកណ្តាលរបស់អង្គការការីតាសកម្ពុជា។

នៅក្នុងកិច្ចប្រជុំនេះ លោកអភិបាលក៏បានធ្វើបទបង្ហាញ សង្ខេបអំពីព្រះសហគមន៍ភូមិភាគភ្នំពេញ។ លោកបញ្ជាក់ថា ភូមិភាគភ្នំពេញ មានព្រះសហគមន៍ចំនួន ៣៨ កន្លែង មានគ្រីស្តបរិស័ទ ចំនួនប្រមាណ១៤០០០នាក់ ដែល៧៥%ជាជនជាតិវៀតណាម។ មានបូជាចារ្យចំនួន ៤២នាក់ ក្នុងនោះមានជាតិកម្ពុជា ចំនួន២នាក់។ មានក្រុមគ្រួសារអ្នកបួសចំនួន៣៨ក្រុម មានដូនជីចំនួន ៧០នាក់ បងប្រុសចំនួន២០នាក់ សាសនទូតគ្រីស្តបរិស័ទ ចំនួន ២០នាក់ និង បុគ្គលិកពេញម៉ោងចំនួន២០០នាក់។

សម្រាប់កម្មវិធីអប់រំចំណេះដឹងទូទៅ លោកអភិបាលមានប្រសាសន៍ថា ព្រះសហគមន៍មានវិទ្យាស្ថានជាន់ខ្ពស់ វិទ្យាល័យ អនុវិទ្យាល័យ មណ្ឌលវប្បធម៌ មណ្ឌលនិស្សិត សាលាមត្តេយ្យ២៥កន្លែង និងកម្មវិធីអក្ខរកម្ម។

ក្នុងពេលនេះគណៈកម្មការដើម្បីសុខភាព និងគណៈកម្មការដើម្បីកុមារ និងយុវជនបានបង្ហាញសកម្មភាព និងបញ្ហាប្រឈមដែលគណៈកម្មការបានជួបប្រទះ និងគម្រោងការរបស់ខ្លួន។ នៅភូមិភាគភ្នំពេញមាន មណ្ឌលទទួលអ្នក ជំងឺបណ្តោះអាសន្នចំនួន២ កន្លែងនៅភ្នំពេញ។

អង្គប្រជុំក៏បានរិះគិតផងដែរសមាប្រប់ថ្ងៃអនាគត គឺទី១ ការចងក្រងជាបណ្តាញ អង្គការកាតូលិកដោយសហការណ៍គ្នាយ៉ាងជិតស្និទ្ធ។ ទី២ ចែករំលែក បទពិសោធន៍ ព័ត៌មាន ចំណេះ និងជំនាញ។ ទី៣ ការរក្សាអត្តសញ្ញាណរបស់ខ្លួនជាកាតូលិក។

អង្គការកាតូលិក តែងជួបជុំគ្នារៀងរាល់បីខែម្តងក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។

The Catholic NGOs and Catholic religious groups met with Bishop OlivierSchmitthaeusler at Caritas headquarters in Phnom Penh, the capital city of Cambodia Penh on September 17, 2011.

The meeting discussed future plans for their work in the diocese. Three objectives were identified: to build a network with strong collaboration among all Catholic NGOs; to share information, experience, and knowledge: and to keep theirCatholicidentity.

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ ថ្ងៃអាទិត្យ ទី២(

អាទិត្យមុន ខ្ញុំនៅទីក្រុងម៉ាឌ្រីដប្រទេសអេស្ប៉ាញ រួមជាមួយសម្តេចប៉ាប។ អភិបូជាកាលពីអាទិត្យមុន ខុសពីអភិបូជានៅថ្ងៃនេះ។ អាទិត្យមុន មានមនុស្ស២លាននាក់ចូលរួម ខ្ញុំមិនធ្លាប់បានឃើញមនុស្សច្រើនផ្ទាល់ភ្នែកយ៉ាងនេះទេ ធ្លាប់មើលតាមតែកញ្ចក់ទូរទស្សន៍ប៉ុណ្ណោះ។ ក្នុងចំណោម២លាននាក់ មានលោកបូជាចារ្យចំនួន១៥០០០នាក់ មានលោកអភិបាល១០០០នាក់ មានព្រះមហាក្សត្រព្រះមហាក្សត្រីប្រទេសអេស្ប៉ាញ រួមជាមួយយុវជនមកពី១៩៣ប្រទេស ដែលបានជួបជុំគ្នាពេញមួយអាទិត្យ ដើម្បីចែករំលែកអំណរសប្បាយជាមួយគ្នា និងជួបមិត្តភក្តិថ្មី ជាពិសេសគឺជួបជាមួយព្រះយេស៊ូ។

ខ្ញុំគិតថាពេលយើង មានបទពិសោធន៍ដូចនេះ យើងយល់ថា ប្រហែលមានតែសាសនាកាតូលិក ដែលអាចប្រមូលមនុស្សច្រើនដូចនេះ ដើម្បីអធិដ្ឋាន និងដើម្បីជួបជាមួយព្រះយេស៊ូ។ តាមពិតមុនយើងទៅដល់ទីក្រុងម៉ាឌ្រីដ មានគេរិះគន់ថា ការជួបជុំនេះអស់លុយច្រើនពេក និងឥតមានន័យអ្វីសោះ ប៉ុន្តែពេលកម្មវិធីចប់ ទាំងអស់គ្នាបានសរសើរ ព្រោះគ្មាននរណាម្នាក់មានគ្រោះថ្នាក់អ្វីសោះ ហើយមានតែ៥០នាក់ប៉ុណ្ណោះ ដែលមានបញ្ហាសុខភាពតិចតួច ប៉ុន្តែឥតមានបញ្ហាឈ្លោះគ្នាទាល់តែសោះ។ ២លាននាក់សុទ្ធតែយុវជនអាយុពី១៨ ឆ្នាំដល់៣០ឆ្នាំ។

នៅយប់ថ្ងៃសៅរ៍ក្នុងពេលអធិដ្ឋាន ខ្ញុំមានអារម្មណ៍ដូចជាចូលរួមនៅក្នុង concert មួយជា concert កាតូលិកម្យ៉ាង ប៉ុន្តែតាមពិតមិនមែនសោះ ដោយសារវាខុសគ្នាមែនទែន ទីមួយពេលសម្តេចប៉ាប មកដល់យើងទាំងអស់គ្នាទះដៃអបអរសាទរសម្តេចប៉ាប។ សម្តេចប៉ាបមានព្រះជន្ម ៨៤ ឆ្នាំហើយ។ យើងទាំងអស់គ្នាស្រលាញ់ ហើយនិយាយខ្លាំងៗថាៗ "បេណេឌីកតូៗ យើងសប្បាយចិត្ត"។ ក្រោយមកខ្ញុំគិតថា ប្រហែលជាមានយុវជនគេឡើង មានកាយវិការមានអ្វីអស្ចារ្យ ប៉ុន្តែឥតមានអ្វីសោះ មានតែព្រះកាយព្រះគ្រីស្ត។ នៅពេលនោះ ១លាន៨សែននាក់ គេបាននៅស្ងៀមស្ងាត់ មិនមែនធម្មតាទេ ដូចជាយើងនៅក្នុងវិសាលវិហារយ៉ាងធំបំផុត។ ទាំងអស់គ្នាលុតជង្គង់ ខ្ញុំមានអារម្មណ៍ថា លោកអភិបាលស្ងាត់អស់ហើយ តាមសក្ខីភាពដែលខ្ញុំបានស្តាប់ដូចជា គេស្ងាត់ទាំងអស់។ ដោយសារព្រះយេស៊ូយាងមកតាមរយៈព្រះកាយព្រះគ្រីស្ត ណែនាំឲ្យយុវជនទាំងអស់ដែលនៅទីនេះ គេគោរពគេស្រលាញ់ និងចង់បង្ហាញអំពីជំនឿរបស់គេ។ នេះជាការអស្ចារ្យមួយពិតមែន។ ចៃដន្យពេលនោះមានភ្លៀងធំ នាំឲ្យគេរងាខ្លាំង តែគេតស៊ូបានពេញមួយយប់ គេសម្រាកនៅកន្លែងនោះ។ អ្វីដែលសំខាន់នៅពេលនោះ គឺគេស្ងៀមស្ងាត់ ដើម្បីគោរពព្រះកាយព្រះគ្រីស្ត។ នេះធ្វើឲ្យយើងយល់ពីអត្ថបទរបស់សន្តប៉ូលដែលយើងបានស្តាប់។ សន្តប៉ូលមានប្រសាសន៍ថា បើបងប្អូនធ្វើដូច្នេះទើបហៅថា គោរពបម្រើព្រះអង្គតាមរបៀបត្រឹមត្រូវ មិនត្រូវយកតម្រាប់តាមលោកីយ៍នេះឡើយ ត្រូវទុកឲ្យព្រះជាម្ចាស់កែប្រែចិត្តគំនិតបងប្អូន។

ថ្ងៃអាទិត្យពេលយើងស្តាប់អំពីយុវជន យើងគិតថាយុវជនចូលចិត្តដើរលេង យុវជនចូលចិត្តទៅនេះទៅនោះ យុវជនចូលចិត្តរញ៉េររញ៉ៃ យុវជនចូលចិត្តសប្បាយភ្លាមៗ មិនចេះគិតពិចារណា ប៉ុន្តែនៅពេលនោះយើងឃើញ ២លាននាក់ដែលអង្គុយគោរពព្រះយេស៊ូយើងយល់ថា ព្រះយេស៊ូដូចជាគំរូយ៉ាងពិសេស ព្រះយេស៊ូជាព្រះជាម្ចាស់របស់យើងយ៉ាងពិតប្រាកដ។ ព្រះយេស៊ូណែនាំឲ្យជីវិតរបស់យើងមានអត្ថន័យយ៉ាងពិសេស។

ពេលមានបទពិសោធន៍ដូចនេះ យើងយល់មូលហេតុយើងចូលព្រះវិហារ គឺឲ្យជីវិតរបស់យើងរកអត្ថន័យយ៉ាងពិតប្រាកដ។ ដូចសន្តប៉ូលបានថ្លែង មិនត្រូវយកតម្រាប់តាមលោកីយ៍នេះឡើយ ត្រូវទុកឲ្យព្រះជាម្ចាស់កែប្រែចិត្ត

# ៈ២៨ ខែសីហា ២០១១( ម៉ាថាយ ១៦, ២១-២៧ )

គំនិតបងប្អូន។ នៅពេលយើងកសាងជីវិតរបស់យើងលើព្រះយេស៊ូគ្រីស្តយ៉ាងពិតប្រាកដ ជីវិតរបស់យើងនឹងមានអត្ថន័យយ៉ាងពិតប្រាកដដែរ។

បងប្អូនចូលព្រះវិហារនេះ មានមូលហេតុតែមួយគឺរកអត្ថន័យសម្រាប់ជីវិត។ អត្ថន័យនេះគឺព្រះយេស៊ូផ្ទាល់ ណែនាំឲ្យជីវិតរបស់យើង ទៅជាជីវិតមួយដ៏ទូលំទូលាយ យ៉ាងពិតប្រាកដ មិនមែនជាជីវិតដែលចង្អៀត គិតពីជីវិតផ្ទាល់ខ្លួននោះឡើយ។ ដូចព្រះយេស៊ូមានព្រះបន្ទូល នៅក្នុងអត្ថបទគម្ពីរថ្ងៃនេះ "អ្នកបាត់បង់ជីវិតព្រោះតែខ្ញុំ អ្នកនោះនឹងបានជីវិតវិញ..." បើមនុស្សម្នាក់បានពិភពលោកទាំងមូល មកធ្វើជាសម្បត្តិរបស់ខ្លួនតែបាត់បង់ជីវិត តើនឹងមានប្រយោជន៍អ្វី?។ ប្រសិនបើយើងមានអ្វីៗ ទាំងអស់ដែលមាននៅក្នុងពិភពលោកនេះ នៅពេលស្លាប់ទៅ យើងនៅសល់អី?។ ប្រសិនបើពេញមួយជីវិតនេះ យើងគិតតែពីចំណេញ គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន និងគិតតែពីទ្រព្យសម្បត្តិ តើមានប្រយោជន៍អ្វី?។ តាមពិតទ្រព្យសម្បត្តិរបស់យើង គឺព្រះយេស៊ូតែម្តង។ ពេលយើងបានឃើញ២លាននាក់នៅខាងមុខព្រះកាយព្រះគ្រីស្ត ដោយស្ងៀមស្ងាត់។ យើងយល់ថា ព្រះយេស៊ូគ្រីស្តពិតជាទ្រព្យសម្បត្តិរបស់យើងប្រាកដមែន។ នាំឲ្យយើងមានកម្លាំងថែមទៀត ដើម្បីផ្តល់សក្ខីភាពអំពីជីវិតរបស់យើង រកអត្ថន័យយ៉ាងពិតប្រាកដនៅក្នុងព្រះយេស៊ូគ្រីស្ត។ ជីវិតរបស់យើងទៅជាជីវិតដែលភ្លឺស្វាង ដោយសារយើងដើរតាមព្រះយេស៊ូ ជីវិតរបស់យើងមានសុភមង្គលដោយសារយើងសុខចិត្តលះបង់ចោលផលប្រយោជន៍ដើម្បីដើរតាមព្រះយេស៊ូ។ មិនមែនលះបង់ចោល ផលប្រយោជន៍ឥតមានន័យ ប៉ុន្តែលះបង់ចោលផលប្រយោជន៍ដើម្បីដើរតាមព្រះយេស៊ូ នេះជាសេចក្តីសង្ឃឹមរបស់យើង។ ទាំងនេះនាំឲ្យជីវិតរបស់យើងទទួលពន្លឺយ៉ាងពិតប្រាកដ គឺព្រះយេស៊ូផ្ទាល់។ ដូច្នេះនាំឲ្យយើងគិតពិចារណា ហេតុអ្វីយើងចូលព្រះវិហាររាល់ថ្ងៃអាទិត្យ ហេតុអ្វីយើងចង់ដើរតាមព្រះយេស៊ូ? គឺដោយសារ យើងចង់រកអត្ថន័យសម្រាប់ជីវិតរបស់យើង។ ជីវិតដែលគ្មានព្រះជាម្ចាស់ គឺជាជីវិតដែលគ្មានន័យជាជីវិតនៅក្នុងភាពងងឹត។ ជីវិតដែលមានព្រះជាម្ចាស់ ជាជីវិតមានន័យ ជាជីវិតដែលចូលនៅក្នុងពន្លឺយ៉ាងពិតប្រាកដ។

ដូច្នេះនៅពេលនេះ យើងទូលអង្វរព្រះជាម្ចាស់ សូមឲ្យព្រះអង្គជួយយើង ឲ្យយើងយកព្រះយេស៊ូជាគំរូ ឲ្យយើងដើរតាមព្រះយេស៊ូយ៉ាងត្រឹមត្រូវ។ ពេលយើងជួបគ្នាជាមួយលោកអភិបាល លោកបូជាចារ្យ ជាមួយយុវជនទាំងអស់ ដោយសារព្រះយេស៊ូ ព្រះសហគមន៍ណែនាំឲ្យយើងទៅជាគ្រួសារតែមួយយ៉ាងពិតប្រាកដ។ យើងជាបងប្អូនគ្នា មិនមែនដោយសារឈាម គឺដោយសារព្រះយេស៊ូតែម្តង ដោយយើងទាំងអស់គ្នាបានទទួលពិធីជ្រមុជទឹក ហើយយើងទាំងអស់គ្នា ជាសាវ័ករបស់ព្រះយេស៊ូ។ សម្តេចប៉ាបបានលើកទឹកចិត្តយើងទាំងអស់គ្នាជាព្រះសហគមន៍ ឲ្យខិតខំតស៊ូនៅក្នុងជីវិត និងឲ្យយើងខិតខំបង្ហាញអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់អ្នកដទៃ។

នៅពេលនេះយើងសូមទូលអង្វរព្រះអង្គ ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដើម្បីបំភ្លឺណែនាំយើង ឲ្យមានសេចក្តីសុខ និងឲ្យយើងធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយយល់ថា មានតែព្រះយេស៊ូទេដែលប្រទានអត្ថន័យនៃជីវិតរបស់យើងយ៉ាងពិតប្រកដ។ ២ឆ្នាំទៀតយើងទៅប្រេស៊ីល វាឆ្ងាយបន្តិចដូច្នេះយើងកាត់បន្ថយចំនួនយុវជនមកត្រឹមប្រហែល១០នាក់ ប្រសិនបើចង់ទៅច្រើនសុំទៅរកលុយសិន។ ខ្ញុំនិយាយពីថ្ងៃនេះតទៅដូច្នេះមានពេល២ឆ្នាំដើម្បីរកថវិកា ដោយសារព្រះសហគមន៍យើងគ្មានចំណូលសោះ ដូច្នេះអ្នកណាដែលចង់ទៅ ប្រេ-ស៊ីល សុំត្រៀមខ្លួនពីថ្ងៃនេះតទៅ។

# សាលាអប់រំគ្រីស្តបរិស័ទ

*"អ្នកណាដើរពេលថ្ងៃ អ្នកនោះមិនជំពប់ជើងដួលឡើយ ព្រោះគេឃើញពន្លឺរបស់ពិភពលោក។ ផ្ទុយទៅវិញអ្នកណាដែលដើរពេលយប់ អ្នកនោះមុខតែជំពប់ជើងដួលជាមិនខាន*"។ យ៉ូហាន១១.៩-១០

សាលាអប់រំគ្រីស្តបរិស័ទបានបើកទ្វារចាំទទួលស្វាគមន៍បងប្អូនគ្រីសបរិស័ទមកទទួលការអប់រំ។ ឆ្នាំសិក្សាដំបូង ២០១១-២០១២ នឹងចាប់ផ្តើមនៅថ្ងៃទី១៤ តុលា ឆ្នាំ ២០១១ខាងមុខនេះ។

សាលានេះមានគោលបំណង ឲ្យគ្រីស្តបរិស័ទទៅជាក្រុមតែមួយ មានជំនឿមាំមួនទៅលើព្រះបិតា និងមានអំណរសប្បាយ ស្គាល់អំពីព្រះបន្ទូលព្រះជាម្ចាស់មានចិត្តស្រលាញ់ និងចង់បម្រើព្រះសហគមន៍ និងធ្វើជាសាក្សីក្នុងសង្គម។

សាលានេះមានទីតាំងនៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) រាជធានីភ្នំពេញ។

កម្មវិធីសិក្សាមានដូចជា ព្រះគម្ពីរ ព្រឹត្តការណ៍អាថ៌កំបាំងរបស់ព្រះគម្ពីរ ទស្សនវិជ្ជា ក្រមសីលធម៌គ្រីស្តបរិស័ទ ការបណ្តុះបណ្តាលខាងផ្លូវវិញ្ញាណ ព្រះសហគមន៍ បេសកកម្មព្រះសហគមន៍ និងការប្រកាសដំណឹងល្អ។ រយៈពេលសិក្សាមាន ២ឆ្នាំ ស្មើនឹង ៣០៦ម៉ោង។ រាល់សប្តាហ៍ការសិក្សាចាប់ផ្តើមពីថ្ងៃសុក្រ វេលាម៉ោង ៥ល្ងាច រហូតដល់ថ្ងៃសៅរ៍ ម៉ោង ១រសៀល។ លក្ខខណ្ឌជ្រើសរើសសិស្សដែលអាចចូលរៀន គឺជានិស្សិតឆ្នាំទី៣ នៅសកលវិទ្យាល័យ ឬអ្នកដែលបានបញ្ចប់ថ្នាក់ទី១២ហើយ។

សូមបញ្ជាក់សាលានឹងផ្តល់នូវអាហារពេលល្ងាចនៅថ្ងៃសុក្រ និងអាហារពេលព្រឹក និងពេលថ្ងៃត្រង់នៅថ្ងៃសៅរ៍។

*"If you walk during the day, you will have light from the sun, and you won't stumble. But if you walk during the night, you will stumble, because you don't have any light".* John: 10:9-10

The Apostolic Vicariate of Phnom Penh is setting up a school to build up both the knowledge and the faith of Cambodian Catholics.

This school will be located in St. Joseph's Parish at Phsar Tauch, and the new academic class will be starting on October14, 2011. It will offer subjects such as the Bible, the Mystery of the Bible, Philosophy, Morality of Christianity, Spirituality, and Evangelization. The class meets every weekend, from Friday at 5 PM till Saturday at 1:00PM and will have 306 hours of class time over a two-year period.

We have 32 registered student already.





# ក្រុមអ្នកស្ម័គ្រចិត្តនៃសហប្រតិបត្តិការពីជប៉ុន

ក្រុមអ្នកស្ម័គ្រចិត្តជប៉ុន បានមកដល់ប្រទេសកម្ពុជាកាលពី១០ឆ្នាំមុន។ សព្វថ្ងៃមានអ្នកស្ម័គ្រចិត្តចំនួន ៥នាក់ ដែលកំពុងធ្វើការទាក់ទងទៅនឹងសុខភាព ការអប់រំ និងការលើកកម្ពស់ស្ត្រី។ ជាពិសេសក្រុមនេះបានធ្វើការយ៉ាងលំបាកជាមួយក្រុមគ្រួសារដែលរស់នៅលើគំនរសំរាមនៅស្ទឹងមានជ័យជាយក្រុងភ្នំពេញ។ សកម្មភាពទាំងនោះមានដូចជា បង្កើតផ្ទះសម្រាប់កុមារដើម្បីទទួលការអប់រំ កម្មវិធីផ្តល់អាហារូបត្ថម្ភ កម្មវិធីសុខភាព ជួយបង្កើតអាជីពថ្មីដល់គ្រួសារដើម្បីទទួលបានប្រាក់ចំនួល។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមនេះបានធ្វើសកម្មភាពនៅតាមបណ្តាខេត្តមួយចំនួនទៀតដូចជា បាត់ដំបង ស្វាយរៀង កំពង់ស្ពឺ ពោធិ៍សាត់ និងនៅក្រុងភ្នំពេញ មានជាអាទិ៍កន្លែងគំនរសំរាមនៅស្ទឹងមានជ័យជាដើម។

លោក ស៊ីណូដា ម៉ាសាស៊ី មានប្រសាសន៍ថា លោកមានអារម្មណ៍សប្បាយណាស់ ដែលបានមកធ្វើការនៅប្រទេសកម្ពុជា។ លោកក៏បានគូសបញ្ជាក់ពីភាពខុសគ្នារវាងប្រទេសជប៉ុន និងប្រទេសកម្ពុជាផងដែរលោកថា ជប៉ុនជាប្រទេសរីកចម្រើន ប៉ុន្តែមានមនុស្សជាច្រើនអស់សង្ឃឹម។ ចំណែកនៅប្រទេសកម្ពុជាប្រជាជនមានសេចក្តីសង្ឃឹមច្រើន ហើយលោកចង់នាំសេចក្តីសង្ឃឹមទៅប្រទេសខ្លួនវិញ។

ក្រុមអ្នកស្ម័គ្រចិត្តជប៉ុន បានបង្កើតនៅឆ្នាំ១៩៨១ ដោយលោកបូជាចារ្យម៉ាយខល ស៊ីហ្គែល។

The Japanese Lay Missionary Movement (JLMM) came to Cambodia more than fifteen years ago. It was founded by Fr. Michael Siegel in1981. Today JLMM is playing a very important role in developing Cambodian society.

JLMM Lay missionaries operate activities for medical care, the environment, agriculture and support of women and children. They work together with the local people and support programs of social welfare and development organized by local Catholic churches.

In Cambodia JLMM is working with healthcare, literacy education, and support for the independence of women. It began in April, 1992 supporting repatriated Cambodian refugees and those who were working hard for the reconstruction of the country. Now they are working in different places in Cambodia such as Battambang, Pursat, Svay Rieng, and Phnom Penh.

## សកម្មភាព លោក សុខកុមារ អូលីវីយេ ឆ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ក្នុង ខែ កញ្ញា ឆ្នាំ២០១១

| | |
|---|---|
| ថ្ងៃទី ១-៣ ខែកញ្ញា | : សិក្ខាសាលា គណៈកម្មការសង្គហៈ នៅព្រះវិហារ សន្តយ៉ូសែប ( ផ្សារតូច) |
| ថ្ងៃទី ៥ ខែកញ្ញា | : អភិបូជាខួបរបស់អ្នកម្ដាយតេរេសា |
| ថ្ងៃទី ៧-៩ ខែកញ្ញា | : សិក្ខាសាលាគ្រូអប់រំជំនឿ ទូទាំងប្រទេស |
| ថ្ងៃទី ១០ ខែកញ្ញា | : ប្រជុំគណៈកម្មការមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិក |
| ថ្ងៃទី ១១ ខែកញ្ញា | : អគ្គសញ្ញាលាបថ្ងាស នៅព្រះសហគមន៍ជុំគីរី |
| ថ្ងៃទី ១២ ខែកញ្ញា | : ប្រជុំអង្គការកាតូលិក |
| ថ្ងៃទី ១៣ ខែកញ្ញា | : ជួបប្រជុំជាមួយប្រធានធំក្រុមបងប្រុសម៉ារីស |
| ថ្ងៃទី ១៤ ខែកញ្ញា | : ប្រជុំក្រុមប្រឹក្សាប្រតិបត្តិ |
| ថ្ងៃទី ១៥ ខែកញ្ញា | : ពិធីទទួលស្វាគមន៍ គ្រួសារអ្នកជំងឺអេដស៍ នៅក្នុងភូមិសុខសាន្ត ( ខេត្តតាកែវ) |
| ថ្ងៃទី ១៦-១៨ ខែកញ្ញា | : សិក្ខាសាលាក្រុមកាយរិទ្ធិ ក្នុងភូមិភាគភ្នំពេញ |
| ថ្ងៃទី ១៩ ខែកញ្ញា | : ប្រជុំក្រុមប្រឹក្សាព្រះសហគមន៍ |
| ថ្ងៃទី ២០ ខែកញ្ញា | : ពិធីសំណាក់ធម៌សម្រាប់លោកបូជាចារ្យភូមិភាគភ្នំពេញ |
| ថ្ងៃទី ២៣ ខែកញ្ញា | : ប្រជុំក្រុមសាសនទូតក្រៅប្រទេស នាទីក្រុងប៉ារីស |
| ថ្ងៃទី ២៥ ខែកញ្ញា | : បុណ្យគោរពសន្តី តេរេសា និងសន្តប្រ៉ង់ស្វ័រ នៅព្រះសហគមន៍ចំការទៀង ខេត្តតាកែវ |
| ថ្ងៃទី ២៧ ខែកញ្ញា | : ប្រារព្ធបុណ្យភ្ជុំ នៅព្រះសហគមន៍ផ្សារតូច |

## The activities of Bishop Olivier Schmitthaeusler, MEP
## Apostolic Vicar of Phnom Penh, September 2011

| | |
|---|---|
| September 1-3, 2011 | : Charity Committee Seminar in the Apostolic of Phnom Penh, |
| September 5, 2011 | : Anniversary mass for Mother Teresa |
| September 7-9, 2011 | : Catechist National Seminar |
| September 10, 2011 | : Catholic Church Student Center Board Meeting |
| September 11, 2011 | : The confirmation Sacrament at Chumkiri Parish |
| September 12, 2011 | : Catholic NGOs Meeting |
| September 13, 2011 | : Meeting with the Superior of Marist Brother |
| September 14, 2011 | : Mission Council Meeting |
| September 15, 2011 | : Welcome HIV/ AIDs family to new village in Takeo (Phum Sok San) |
| September 16-18, 2011 | : Scout Seminar |
| September 19, 2011 | : Episcopal Council Meeting |
| September 20, 2011 | : Priest retreat (Phnom Penh Vicariate) |
| September 23, 2011 | : MEP Meeting |
| September 25, 2011 | : Feast of St. Teresa and St. Francis |
| September 27, 2011 | : Pchum Ben Day (Mass at Phsa Touch ) |